Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Feb-2021, 09:10
CMS/CFO: Sann Rada

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Maureen Harding CLARK**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# ដីកាចាត់តាំងចៅក្រមរបាយការណ៍

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Brenda HOLLIS

**<u>ជនជាប់ចោទ</u>**
ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Megan HIRST

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F59

**យើង** ចៅក្រម **គង់ ស្រ៊ឹម** ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩

**កត់សម្គាល់ឃើញ**ថា នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម និងប្រកាសទោសក្នុងសំណុំរឿង ០០២/០២ ដោយផ្ទាល់មាត់នូវសេចក្តីសង្ខេបនៃការយល់ឃើញរបស់ខ្លួន និងផ្នែកសម្រេចសេចក្តីនៃសាលក្រម[1]

**កត់សម្គាល់ឃើញ**ថា សាលក្រមជាលាយលក្ខណ៍អក្សរបន្ទាប់មកត្រូវបានចេញជាភាសាខ្មែរ បារាំង និងអង់គ្លេស នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ (“សាលក្រមអង្គជំនុំជម្រះសាលាដំបូង”)[2]

**ដោយបានទទួល**បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា[3] និង ខៀវ សំផន[4]

**អនុលោមតាម**វិធាន ១០៨(៥)[5]នៃវិធានផ្ទៃក្នុង ប្រធានអង្គជំនុំជម្រះតុលាការកំពូលត្រូវចាត់តាំងចៅក្រមជាតិ និងអន្តរជាតិធ្វើជាចៅក្រមរបាយការណ៍ ដើម្បីពិនិត្យ និងផ្តល់ព័ត៌មានពេញលេញស្តីពីបណ្តឹងសាទុក្ខដល់អង្គជំនុំជម្រះ

---

[1] ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1។

[2] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ E465។

[3] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F50។

[4] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (សំណុំរឿង ០០២/០២) ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ F54។

[5] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. វិសោធនកម្មលើកទី ៩ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥។

**ពិចារណា**ទៅលើបញ្ហាដែលបានលើកឡើងក្នុងបណ្ដឹងសាទុក្ខមានលក្ខណៈច្រើនសន្ធឹកសន្ធាប់ និង ដើម្បីអត្ថប្រយោជន៍យុត្តិធម៌នៃការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព តម្រូវឱ្យចាត់តាំងសហចៅក្រម របាយការណ៍តាមផ្នែកនៃបញ្ហាដែលបានលើកឡើងក្នុងបណ្ដឹងសាទុក្ខនេះ[6]

## អាស្រ័យហេតុនេះសម្រេចចាត់តាំង៖

១. ចៅក្រម **Judge Chandra Nihal JAYASINGHE** និងចៅក្រម **ម៉ុង មុន្នីចរិយា** ជាសហចៅក្រមរបាយការណ៍សម្រាប់រាល់បញ្ហាទាំងឡាយនៃបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និងការប្រកាសទោស

២. ចៅក្រម **Florence Ndepele Mwachande MUMBA** និងចៅក្រម **យ៉ា ណារិន** ជាសហចៅក្រមរបាយការណ៍សម្រាប់រាល់បញ្ហានៃបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធ និងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

៣. ចៅក្រម **Maureen Harding CLARK** និងចៅក្រម ***សោម សិរីវឌ្ឍ*** ជាសហចៅក្រមរបាយការណ៍លើរាល់បញ្ហាទាំងឡាយនៃបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ ខៀវ សំផន។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**

[6] *សូមមើល* ដីកាចាត់តាំងសហចៅក្រមរបាយការណ៍សម្រាប់សំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារលេខ F25 និងសំណុំរឿង ០០១ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ F21 (អនុម័តវិធីសាស្ត្រដូចគ្នា)។